# ការមានចិត្តរសាប់រសល់អាចទាក់ទងទៅនឹងបញ្ហាសុខភាព

**Anxiety Disorders Tied to Physical Illness**
**WUML**
**11/5/06**

យោលទៅតាមការសិក្សាស្រាវជ្រាវមួយថ្មីៗនេះ បានឲ្យដឹងថា ការមានចិត្តរសាប់រសល់ អាចមានជាប់ទាក់ទង ទៅនឹងបញ្ហាសុខភាពជាច្រើន រួមទាំងការឈឺសន្លាក់ដៃសន្លាក់ជើង, ឈឺក្បាលពុំបាត់ដែលខ្មែរយើងហៅថាឈឺប្រកាំង, ឈឺប្រព័ន្ធដកដង្ហើម, ឈឺក្រពះ, , Allergies, និងមានបញ្ហាក្រពេញចំពង់ករដែលហៅថា Thyroid។

នៅក្នុងការសិក្សាថ្មីនេះ អ្នកស្រាវជ្រាវនៅប្រទេសកាណាដាបានធ្វើការវិភាគជាមួយមនុស្សចំនួនជិត 4,200 នាក់ដែលចូលរួមជាមួយការស្ទង់មតិរបស់ក្រសួងសុខភាពអាឡឺម៉ង់ នៅចន្លោះឆ្នាំ 1997 ទៅឆ្នាំ 1999។  ចំនួនអ្នកចូលរួមក្នុងការសិក្សានេះ 8.4% មានការរសាប់រសល់ក្នុងកំឡុងពេលមួយខែមុន ហើយ ចំនួន 60.8% មានបញ្ហាសុខភាព។

ការសិក្សានេះបានបញ្ជាក់ឲ្យដឹងថា អ្នកចូលរួមដែលមានការរសាប់រសល់និងបញ្ហាសុខភាពភាគច្រើន មានបញ្ហាផ្លូវចិត្តរសាប់រសល់ មុនពេលដែលមានបញ្ហាសុខភាព ហើយច្រើនមានរបៀបរស់នៅពុំសូវល្អ ជាងអ្នកដែលគ្រាន់តែមានបញ្ហារសាប់រសល់ឬបញ្ហាសុខភាពមួយមុខប៉ុណោះ។

សារពត៌មាន វិជ្ជាពេទ្យសំរាប់មនុស្សពេញវ័យ ហៅថា Archives of Internal Medicine ចុះផ្សាយនៅ ថ្ងៃទី 23 ខែ តុលាកន្លងមកនេះ បានថែងថា អ្នកធ្វើការស្រាវជ្រាវនៅពុំទាន់ដឹងឲ្យច្បាស់លាស់ អំពីមូលហេតុនៃទំនាក់ទំនង រវាងការរសាប់រសល់និងបញ្ហាសុខភាពនៅឡើយទេ។ ប៉ុន្តែ មានកត្តាជាច្រើនដែលគួរយកចិត្តទុកដាក់ ពិចារណា។

ឧទាហរណ៍ ដូចជា ការមានជម្ងឺផ្លូវកាយច្រើន អាចបណ្តាលឲ្យអ្នកជម្ងឺពិបាកចិត្តនិងរសាប់រសល់ ដែលជាអាចចាត់ទុកថា ជាជម្ងឺរសាប់រសល់ ឬ Anxiety Disorder បាន។  ឯការមានចិត្តរសាប់រសល់វិញ អាចធ្វើប្រព័ន្ធរាងកាយផ្លាស់ប្តូរ ចុះដុនដាបរហូតដល់មានជម្ងឺ ឬជួនកាលរហូតដល់ទៅមានបញ្ហាម្យ៉ាងទៀត គឺការទទួលទានសុរាហួសកំរិត ឬក៏មានបញ្ហាផ្លូវកាយ និងផ្លូវចិត្ត ជាមួយគ្នាតែម្តង។

អ្នកនិពន្ធសារពត៌មាននេះមានប្រសាសន៍ថា ទោះបីជាពេលឥឡូវនេះ នៅមានការខំប្រឹងប្រែងដើម្បីព្យាបាលជម្ងឺធ្លាក់ទឹកចិត្តដែលហៅថា Depression យ៉ាងណាក៏ដោយ ក៏ការស្រាវជ្រាវថ្មី

នេះ បានបញ្ជាក់ ឲ្យយើងដឹងថា គួរមានកម្មវិធីផ្សេងៗ សំរាប់ព្យាបាលជម្ងឺរសាប់រសល់និង ជម្ងឺផ្លូវកាយ ជាមួយគ្នាផងដែរ។

ចំពោះពត៌មានបន្ថែមស្តីអំពីជម្ងឺរសាប់រសល់, Anxiety Disorders, សូមមេត្តាអានវិបសៃ របស់សមាគមន៍អាមេរិកាំង ខាងផ្នែកជម្ងឺរសាប់រសល់ ហៅថា Anxiety Disorders Association of America ដែលមាន អាសយដ្ឋាន www.adaa.org ។

*អត្ថបទនេះដកស្រង់និងបកប្រែចេញពីសារពត៌មាន Healthfinder នៃ ក្រសួងសុខភាព និងមនុស្សធម៌ U.S. Department of Health and Human Services។ ដោយ មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាព សហគមន៍ក្រុងឡូវែល។*

http://www.healthfinder.gov/news/newsstory.asp?DocID=535668